ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកំពង់ឆ្នាំង**

-សំណុំរឿងព្រហ្មទណ្ឌលេខ **៣៨៨**

ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៣។

**-សាលក្រមលេខ ០៤ "ឃ"**

ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០២០។

# សាលក្រមមុនអង្គសេចក្តី

# តាងនាមប្រជារាស្ត្រខ្មែរ

# សាលាដំបូងខេត្តកំពង់ឆ្នាំង

បានបើកសវនាការជាសាធារណៈ នៅសាលាជម្រះក្តីនៃសាលាដំបូងខេត្តកំពង់ឆ្នាំង នាថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០២០ វេលាម៉ោង ០៨ និង ៣០ នាទីព្រឹក ដោយមានសមាសភាពដូចតទៅ៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] **ជាប្រធានក្រុមប្រឹក្សា**

លោក [redacted] **ជាចៅក្រមក្រុមប្រឹក្សា**

លោក [redacted] **ជាចៅក្រមក្រុមប្រឹក្សា**

**តំណាងអយ្យការ**

លោក [redacted] ជាព្រះរាជអាជ្ញារង អមសាលាដំបូងខេត្តកំពង់ឆ្នាំង។

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ជាក្រឡាបញ្ជី នៃសាលាដំបូងខេត្តកំពង់ឆ្នាំង។

ដើម្បីជំនុំជម្រះមុនអង្គសេចក្តីលើសំណុំរឿងព្រហ្មទណ្ឌលេខ៣៨៨ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៣ ស្តីពីការសម្រេចពីការឃុំខ្លួនបណ្តោះអាសន្ន ទៅលើជនជាប់ចោទ៖

១- ឈ្មោះ [redacted] **ខុន** ភេទប្រុស អាយុ ៧២ ឆ្នាំ ជាតិខ្មែរ មុខរបរមេភូមិ នៅភូមិ[redacted] ខេត្តកំពង់ឆ្នាំង, ឪពុកឈ្មោះ[redacted] ម៉ិច(ស), ម្តាយឈ្មោះ[redacted] យ៉ែម(រ) ប្រពន្ធឈ្មោះ [redacted] ភីម មានកូន ០៦ នាក់, ទោសពីមុនៈ គ្មាន។

**មេធាវីៈ** លោក [redacted] ការិយាល័យកំពង់ឆ្នាំង ការពារសិទ្ធិឱ្យជនជាប់ចោទ។

ត្រូវផ្តន្ទាទោសចំនួន ០២ (ពីរ) ឆ្នាំ និង ០៦ (ប្រាំមួយ) ខែ ពីបទៈ **"ក្លែងបន្លំ និងប្រើប្រាស់លិខិតក្លែង"** តាមមាត្រា៦២៦, មាត្រា៦២៧ និងមាត្រា៦២៨ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅភូមិលាជ ឃុំអូរឬស្សី ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០១០ និងថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១២។

**អង្គហេតុ និងដំណើររឿងមានដូចតទៅ៖**

កាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០១០ ឈ្មោះ [redacted] សារីម បានលួងលោមប្រជាពលរដ្ឋចំនួន ៣៤ គ្រួសារ នៅឃុំអូរឬស្សី ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ឱ្យផ្តិតមេដៃលើលិខិតផ្ទេរសិទ្ធិឱ្យខ្លួនជាតំណាងផ្លូវនិងប្រាក់ ១០០ (មួយរយ)ដុល្លារ ក្នុងការទាមទារដីស្រែទំហំ២៦.៣១៤០ ហិចតា។ ក្រោយមកឈ្មោះដួង សារីម,

Scanned with CamScanner

និងគួកនបានធ្វើកិច្ចសន្យាផ្ទេរសិទ្ធិមួយទៀតក្លែងបន្លំឲ្យខ្លួនមានសិទ្ធិក្នុងការចាត់ចែង លក់ដូរបញ្ចាំ ឬ ជួលឲ្យបុគ្គលឯកជន អង្គភាព ឬក្រុមហ៊ុនណាក៏បាន ហើយបានយកដីរបស់ខ្លួនលក់ឲ្យទៅឈ្មោះ [redacted] ណាស់ អាពីទីនក្នុងតម្លៃ ៣៥,០០០ (បីម៉ឺនប្រាំពាន់)ដុល្លារ។ ក្រោមកទៀតនៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១២ ឈ្មោះដួង សារឹម និងគួកន បាន យកអត្តសញ្ញាណអ្នកដទៃមកក្លែងបន្លំធ្វើជាម្ចាស់ដីដើម និងយកមនុស្សដែលបានស្លាប់ទៅមកផ្តិតមេដៃឲ្យខ្លួនធ្វើ ជាតំណាងក្នុងការចូលខ្លួនទៅបំភ្លឺពាក់ព័ន្ធ និងទំនាក់ទំនងផ្លូវច្បាប់ គ្រប់ស្ថាប័ន និងសមត្ថកិច្ចផ្សេងៗ ព្រមទាំងសម្រេចរាល់ភារកិច្ច។ បានលិខិតផ្ទេរសិទ្ធិតំណាងនេះហើយ សាលាដំបូងខេត្តកំពង់ឆ្នាំង បានចេញដីកាសម្រេច រក្សាការពារលេខ ០៧ ដ.ក.រ.ក.ព ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១២ ហាមមិនឲ្យឈ្មោះ[redacted] លេម៉េង និងឈ្មោះ[redacted] ស៊ុងអៀន ដែលអស់សិទ្ធជាម្ចាស់កម្មសិទ្ធិលើដីខាងលើទៅហើយនោះ មិនឲ្យលក់ ផ្ទេរ សាងសង់ ធ្វើមរតក ធ្វើអំ ណោយ នូវដីរបស់ខ្លួនឲ្យទៅជនដទៃឡើយ។

## នាពេលសវនាការ

១- ជនជាប់ចោទឈ្មោះ [redacted] ខុន បានឆ្លើយបំភ្លឺថា: ខ្លួនត្រូវចាប់ខ្លួននៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២០ និងត្រូវនាំមកតុលាការនៅពេលនេះ។ បច្ចុប្បន្ននេះ ខ្លួនមានអាយុ ៧២ ឆ្នាំហើយ និងមានជំងឺទើបតែវះកាត់រួច បានប្រហែល ១០ ថ្ងៃតែប៉ុណ្ណោះ។ សព្វថ្ងៃនេះ ខ្លួនមានអាការៈឈឺពេញខ្លួន ក្តៅ និងរាងហ៊ត់ខ្លះៗដែរ។ ចំពោះជំងឺនេះ ខ្លួនមានសំបុត្រពេទ្យបញ្ជាក់ត្រឹមត្រូវ ហើយក្នុងមួយខែម្តងត្រូវជួបពេទ្យតាមណាត់។ ចំពោះការមិនបានចូលសវនាការកន្លងមកនេះ គឺដោយសារតែខ្លួនឈឺនៅពេទ្យ។

២- តំណាងអយ្យការលោក [redacted] បានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា: ឆ្លងតាមការពិភាក្សាដេញដោល យល់ឃើញថា ជនជាប់ចោទឈ្មោះ [redacted] ខុន ភេទប្រុស ដែលជាប់ចោទពីបទ ក្លែងបន្លំ និងប្រើប្រាស់លិខិតក្លែង នេះ មានវ័យចាស់ជរា និងមានជំងឺប្រចាំកាយទៀតផង។ ដូច្នេះ ស្នើសុំតុលាការពិនិត្យពិចារណាលើស្ថានភាពជាក់ស្តែងរបស់ជនជាប់ចោទខាងលើនេះ។

៣- លោក [redacted] មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា: ក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ សូមគាំទ្រការលើកឡើងរបស់តំណាងអយ្យការ ព្រោះថាកូនក្តីខ្លួនមានជំងឺ (មានសំបុត្រពេទ្យបញ្ជាក់) និងមានវ័យ ៧២ ឆ្នាំទៅហើយ។ ដូច្នេះការឃុំខ្លួនគាត់ ជារឿងមួយមិនសមហេតុផលនោះទេ។ ហេតុនេះ ស្នើតុលាការមេត្តាសម្រេចមិនឃុំកូនក្តីខ្លួន។

**៤- សំដីចុងក្រោយ:** សូមតុលាការមេត្តាកុំឃុំខ្លួន ព្រោះខ្លួនមានជំងឺប្រចាំកាយ។

## <u>សំអាងហេតុ</u>

**១- យល់ឃើញថា:** សំបុត្រពេទ្យចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២០ អាចបញ្ជាក់ថាជនជាប់ចោទឈ្មោះ [redacted] ខុន ភេទប្រុស អាយុ ៧២ ឆ្នាំ កំពុងមានជំងឺប្រចាំកាយពិតមែន ដែលត្រូវសម្រាកព្យាបាលជំងឺជាចាំបាច់ ព្រមទាំងត្រូវជួបគ្រូពេទ្យតាមការណាត់។ម្យ៉ាងទៀតជនជាប់ចោទរូបនេះ មានអាសយដ្ឋាន, មុខរបរពិតប្រាកដ និងជនជាប់ចោទមានវ័យចាស់ណាស់ទៅហើយ គប្បីតុលាការពិចារណាលើសេរីភាពជាមូលដ្ឋានស្របតាមមាត្រា ២០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

Scanned with CamScanner

**២- យល់ឃើញថា:** ការឃុំខ្លួនលើជនជាប់ចោទឈ្មោះ [redacted] ខុន ភេទប្រុស អាយុ៧២ ឆ្នាំ ពុំមានភាពចាំបាច់ ស្របតាមមាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌឡើយ។

**ហេតុដូច្នេះវិនិច្ឆ័យសេចក្តី**

១- មិនឃុំខ្លួនលើជនជាប់ចោទឈ្មោះ [redacted] **ខុន** ភេទប្រុស អាយុ ៧២ ឆ្នាំ ជាតិខ្មែរ មុខរបរជាមេភូមិ កើតនិងរស់នៅភូមិ [redacted] ខេត្តកំពង់ឆ្នាំង, ឪពុកឈ្មោះ [redacted] ម៉ិច (ស), ម្តាយឈ្មោះ [redacted] យ៉ែម (ស) ប្រពន្ធឈ្មោះ [redacted] ភឹម មានកូន ០៦ នាក់, ទោសពីមុន: គ្មាន។

ដែលជាប់ចោទពីបទ "**ក្លែងបន្លំ និងប្រើប្រាស់លិខិតក្លែង**" តាមមាត្រា ៦២៦, មាត្រា ៦២៧ និង មាត្រា ៦២៨ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅភូមិលាជ ឃុំអូរឬស្សី ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០១០ និងថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១២។

២-សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ នៅថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២០ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ខុន។ ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សា** |
| --- | --- | --- |
| ហត្ថលេខា និងត្រា | [redacted] | |

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃសុក្រ ០៤ រោច ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

កំពង់ឆ្នាំង, ថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០២០

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ប្រធានក្រុមប្រឹក្សា**

[redacted]